**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ:១៩៧.៣៨.សរជ.ណា ៣ថ

ថ្ងៃ អង្គារ ៥ កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ជម្រាបជូន**

**-ឯកឧត្តមបណ្ឌិត ថោង ខុន ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**
**-ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**
**-ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តសៀមរាប**

**កម្មវត្ថុ៖** ករណីរបាយការណ៍លទ្ធផលសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២៥-២០២៨"។

**យោង ៖**- លិខិតលេខ០០២ របក.គអទស ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៤ របស់គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលបានឃើញនិងសូមអរគុណចំពោះរបាយការណ៍លទ្ធផលសិក្ខាសាលាពិគ្រោះយោបល់ស្តីពី "ការរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២៥-២០២៨" និងសម្រេច ដូចខាងក្រោម៖

- ឯកភាពជាគោលការណ៍ឱ្យគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ (**គ.អ.ទ.ស.**) ជាសេនាធិការជួយរាជរដ្ឋាភិបាល ក្នុងការតាមដាន ត្រួតពិនិត្យ សម្របសម្រួល ជំរុញការអនុវត្តការងារលើវិស័យទេសចរណ៍នៅខេត្តសៀមរាបជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរអប្សរា អាជ្ញាធរពាក់ព័ន្ធ និងវិស័យឯកជន (ដោយមិនលូកដៃចូលធ្វើការជំនួសក្រសួង ស្ថាប័នជំនាញ លើកលែងតែការអនុវត្តគម្រោងគំរូណាមួយដែលរាជរដ្ឋាភិបាលប្រគល់ភារកិច្ច) និងរាយការណ៍ជាប្រចាំជូន **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ដើម្បីសុំអនុសាសន៍ណែនាំ និងការសម្រេចដ៏ខ្ពង់ខ្ពស់។

- ឯកភាពជូន **គ.អ.ទ.ស.** ជួយរាជរដ្ឋាភិបាល ក្នុងការតាមដាន វាយតម្លៃលើការអនុវត្តការងារលើវិស័យទេសចរណ៍នៅខេត្តសៀមរាប និងរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីសម្រេច។

- ករណីមានការប្រគល់ភារកិច្ចពីប្រមុខរាជរដ្ឋាភិបាលលើកិច្ចការងារណាមួយជាក់លាក់ ត្រូវទទួលដឹកនាំសម្របសម្រួលជាមួយស្ថាប័ន ក្រសួងពាក់ព័ន្ធ ដើម្បីជំរុញអនុវត្តដោយជោគជ័យ។

- ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងទេសចរណ៍ ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (CTB) និងរដ្ឋបាលខេត្តសៀមរាប ដើម្បីរួមគ្នាលើកកម្ពស់វិស័យទេសចរណ៍ក្នុងខេត្តសៀមរាបឱ្យកាន់តែខ្លាំងក្លា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមជ្រាប និងចាត់ចែងអនុវត្ត។

**ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**យឿង ណាត**

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អាជ្ញាធរអប្សរា
- គ្រឹះស្ថានអង្គរ
- ឯកសារ កាលប្បវត្តិ